## គោលការណ៍ និងល័ក្ខខ័ណ្ឌរបស់កម្មវិធី

## “បង់រំលស់ការប្រាក់ 0% គ្រប់ពេលវេលាគ្រប់ទីកន្លែង”

មុនពេលចុះឈ្មោះក្នុងកម្មវិធី បង់រំលស់ការប្រាក់ 0% គ្រប់ពេលវេលាគ្រប់ទីកន្លែង (បង់រំលស់) ជាមួយប័ណ្ណឥណទានធនាគារ សាខមប៉ែង (ខេមបូឌា) (ប័ណ្ណ) សូមអតិថិជនមេត្តា អានឲ្យបានច្បាស់នូវគោលការណ៍ និងល័ក្ខខ័ណ្ឌរបស់កម្មវិធីដែលមានដូចខាងក្រោមនេះ។ នៅពេលដែលអតិថិជនចុះឈ្មោះប្រើប្រាស់សេវាកម្មបង់រំលស់គឺ មានន័យថា អតិថិជនបានយល់ព្រម នូវរាល់ការកំណត់របស់គោលការណ៍ និងល័ក្ខខ័ណ្ឌនេះ។ រាល់ចម្ងល់ឬ សំនួរពាក់ព័ន្ធនឹងកម្មវិធីនេះ សូមធ្វើការហៅមកកាន់ភ្នាក់ងារបម្រើអតិថិជនលេខ 023223423។

**1. ល័ក្ខខ័ណ្ឌដើម្បីចូលរួមកម្មវិធី:**

1.1. កម្មវិធីបង់រំលស់ត្រូវបានអនុវត្តចំពោះតែអតិថិជនដែលជាឯកត្តជន ហើយជាម្ចាស់ប័ណ្ណឥណទានវិសារបស់ធនាគារសាខមប៉ែង(ខេមបូឌា) (តទៅហៅថាម្ចាស់ប័ណ្ណ ឬអតិថិជន)។

1.2. កម្មវិធីបង់រំលស់ត្រូវបានអនុវត្តចំពោះតែប្រតិបត្តិការទិញទំនិញ ប្រើប្រាស់សេវាកម្មដោយទូទាត់តាមរយៈប័ណ្ណឥណទានវីសា និងមិនអនុវត្តចំពោះប្រតិបត្តិការដក់សាចប្រាក់ ប្រតិបត្តិការដែលស្រដៀងនឹងប្រតិបត្តិការដក់សាចប្រាក់ ដូចជាៈ ប្រតិបត្តិការទិញមាស ទិញគ្រឿងអលង្ការ ទិញរូបិយប័ណ្ណបរទេស និងកម្រៃសេវាកម្មផ្សេងៗរបស់ប័ណ្ណឥណទាន (រួមមានកម្រៃសេវាផ្តល់ប័ណ្ណ និងកម្រៃសេវាដែលកើតមានពេលប្រើប្រាស់ប័ណ្ណ ដែលមិនរាប់បញ្ចូលកម្រៃសេវាផ្លាស់ប្តូររូបិយប័ណ្ណបរទេស)។ ជាមួយគ្នានោះដែរ រាល់ប្រតិបត្តិការទាំងអស់ត្រូវបានទូទាត់រួចរាល់(settle) នៅក្នុងប្រព័ន្ធមុនពេលចុះឈ្មោះប្រើប្រាស់សេវាកម្ម បង់រំលស់។

1.3. កម្មវិធីបង់រំលស់នឹងមិនត្រូវបានអនុវត្តក្នុងករណីៈ (ក)វិធីបង់រំលស់ដែលអតិថិជនចុះឈ្មោះមានភាគរយ/តម្លៃ នឹង/ឬរយៈពេលនៃការបង់រំលស់តិចជាងរយៈពេលអប្បរមាដែលកំណត់របស់កម្មវិធីជាក់ស្តែង ឬ(ខ) គណនីប័ណ្ណឥណទានរបស់អតិថិជនស្ថិតនៅក្នុងស្ថានភាពយឺតយ៉ាវក្នុងការទូទាត់ ឬ(គ) ម្ចាស់ប័ណ្ណមិនបានគោរពតាមគោលការណ៍ និងល័ក្ខខ័ណ្ឌនៃការផ្តល់ប័ណ្ណ និងការប្រើប្រាស់ប័ណ្ណឥណទានរបស់ធនាគារ ឬ(ឃ) ប្រតិបត្តិការដែលបានចុះឈ្មោះបង់រំលស់រួចរាល់ ឬ(ង) សមតុល្យរបស់ប័ណ្ណឥណទានមិនគ្រប់លក្ខខ័ណ្ឌដែលបានកំណត់របស់ធនាគារនៅតាមគ្រានីមួយៗ នៅពេលដែលធនាគារធ្វើការផ្លាស់ប្តូរទៅបង់រំលស់។

(*) ប្រភេទប្រតិបត្តិការត្រូវផ្អែកទៅតាម MCC – Merchant Category Code តាមការកំណត់របស់មជ្ឈមណ្ឌលប័ណ្ណ ជាមួយនឹងកន្លែងទទូលទូទាត់ប័ណ្ណ។

**2. ការទិញទំនិញនឹងធ្វើការចុះឈ្មោះប្រើប្រាស់សេវាកម្មបង់រំលស់:**

2.1. ពេលចុះឈ្មោះប្រើប្រាស់សេវាកម្មបង់រំលស់ អតិថិជនមិនតម្រូវអោយធ្វើការទូទាត់ការប្រាក់ដែលកើតមានទៅលើប្រតិបត្តិកាដែលត្រូវបង់រំលស់នោះទេ ក្នុងនឹងលក្ខខ័ណ្ឌអតិថិជនធ្វើការចុះឈ្មោះប្រើប្រាស់សេវាបង់រំលស់ ក្រោយពេលដែលប្រតិបត្តិការត្រូវបានធ្វើការទូទាត់រួចរាល់នៅក្នុងប្រព័ន្ធ(មិនលើសពីថ្ងៃសរុបប្រតិបត្តិការ)។

2.2. ធនាគារសាខមប៉ែង ខេបូឌា នឹងធ្វើការកត់ត្រាចំនួនទឹកប្រាក់របស់ប្រតិបត្តិការរបស់ប័ណ្ណឥណទាន ដែលបានដែលបានចុះឈ្មោះសេវាកម្មបង់រំលស់ដោយជោគជ័យ ទៅជាគណនីបង់រំលស់ប្រចាំខែអាស្រ័យទៅលើរយៈពេលដែលអតិថិជនតិថិជនបានជ្រើសរើស និងត្រូវស្របតាមការកំណត់របស់ធនាគារសាខមប៉ែងទៅតាមគ្រានីមួយៗ។ ចំនួនទឹកប្រាក់ដែលត្រូវទូទាត់ត្រលប់នឹងត្រូវបានទូទាត់ជាច្រើនដង និងគណនីត្រូវសង (រួមមានចំនួនទឹកប្រាក់បង់រំលស់ និងកម្រៃសេវាកម្មបង់រំលស់) របស់ខែដំបូងនឹងត្រូវបញ្ចូលទៅក្នុងគណនីប័ណ្ណឥណទានភ្លាមៗ ឬនៅថ្ងៃដែលធនាគារបាន

កំណត់។

2.3. ចំនួនទឹកប្រាក់សរុបដែលធ្វើការបង់រំលស់ត្រូវចែកនឹងចំនួនខែដែលអតិថិជនបានចុះឈ្មោះស្មើៗគ្នា ហើយត្រូវបានកត់ត្រាជា គណនីសងប្រចាំខែ។ ចំនួនទឹកប្រាក់ដែលត្រូវបង់រំលស់ប្រចាំខែ ត្រូវបានចាត់ទុកជាប្រតិបត្តិការធម្មតា និងជាចំណែកមួយនៃចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់របស់របាយការណ៍ប្រតិបត្តិការណ៍ប័ណ្ណ។

2.4. កម្រិតឥណទានរបស់អតិថិជន នឹងត្រូវបានកាត់បន្ថយស្របជាមួយនឹងចំនួនទឹកប្រាក់នៃប្រតិបត្តិការបង់រំលស់ប្រចាំខែដែលអតិថិជនត្រូវទូទាត់មកធនាគារ។ រៀងរាល់ខែ កម្រិតឥណទានរបស់អតិថិជនត្រូវកើនឡើងស្របជាមួយនឹងចំនួនទឹកប្រាក់ដែលអតិថិជនបានទូរទាត់ត្រលប់មកកាន់ធនាគារ។

2.5. នូវគ្រប់ការកំណត់ របស់គោលការណ៍និងលក្ខខ័ណ្ឌខាងលើនេះ ក្នុងករណីដែលម្ចាស់ប័ណ្ណមិនទូទាត់នូវចំនួនទឹកប្រាក់ដែលត្រូវទូទាត់នៅក្នុងរបាយការណ៍ប្រតិបត្តិការណ៍ប័ណ្ណ ឬមុនថ្ងៃកំណត់ត្រូវទូទាត់ នោះម្ចាស់ប័ណ្ណត្រូវទូទាត់ថែមចំនួនកាប្រាក់របស់សមតុល្យចុងគ្រា ទៅតាមការគោលការណ៍នឹងលក្ខខ័ណ្ឌរបស់ប័ណ្ណឥណទាន ធនាគារសាខមប៉ែងខេមបូឌា។

2.6. ចំនួនទឹកប្រាក់ដែលចុះឈ្មោះប្រើប្រាស់សេវាបង់រំលស់ នឹងត្រូវបានផ្លាស់ប្តូរក្នុងរយៈពេល ០៧ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលអតិថិជនធ្វើការស្នើសុំប្រើប្រាស់សេវាបង់រំលស់ (មិនរាប់បញ្ចូលប្រតិបត្តិការដែលមិនទាន់បានទូទាត់ (settle) ក្នុងប្រព័ន្ធធនាគារ សាខមប៉ែង ខេមបូឌា)។ ក្នុងករណីដែលម្ចាស់ប័ណ្ណទទួលបានការជូនដំណឹងពីប្រតិបត្តិការប៉ុន្តែចំនួនទឹកប្រាក់មិនទាន់បានប្តូរទៅជាបង់រំលស់ ឬម្ចាស់ប័ណ្ណបានទូទាត់ទឹកប្រាក់សមតុល្យមុនកាលកំណត់ នោះម្ចាស់ប័ណ្ណត្រូវធ្វើការទំនាក់ទំនងមកកាន់ភ្នាក់ងារបំរើអតិថិជន។

2.7. ក្នុងករណីដែលម្ចាស់ប័ណ្ណបានទូទាត់មុន ឬប្រតិបត្តិការត្រូវបានទូទាត់ដោយស្វ័យប្រវត្តិ នោះធនាគារនឹងធ្វើការផ្លាស់ប្តូរសេវាកម្មបង់រំលស់តែចំនួនសមតុល្យទឹកប្រាក់ជាក់ស្តែងតែប៉ុនណ្ណោះ (មិនរាប់បញ្ចូល ការប្រាក់ និងថ្លៃសេវា) នៅពេលផ្លាស់ប្តូរសេវាបង់រំលស់ ប្រសិនបើមិនខុសទៅនឹង ប្រការ ១ ចំនុច ១.៣ ខាងលើនេះ។

3. **ការបញ្ចប់កម្មវិធីបង់រំលស់**

3.1. ធនាគារ សាខមប៉ែង ខេមបូឌា មានសិទ្ធិគ្រប់គ្រាន់ក្នុងការលុបចោល ឬបញ្ឈប់ការផ្តល់សេវាកម្មបង់រំលស់ទោះក្នុងពេលណាក៏ដោយ (រួមមានតែមិនចំពោះករណីដូចខាងក្រោមនេះ) ដោយការជូនដំណឹងទៅកាន់ម្ចាស់ប័ណ្ណ តម្រូវអោយម្ចាស់ប័ណ្ណត្រូវទូទាត់ភ្លាមនូវចំនួនទឹកប្រាក់សមតុល្យរបស់ប្រតិបត្តិការណាដែលបានចុះឈ្មោះបង់រំលស់ ពេលកើតមានករណីដូចខាងក្រោមៈ

ក. ម្ចាស់ប័ណ្ណបានប្រព្រឹត្តខុសប្រការណាមួយនៅក្នុងគោលការណ៍និងលក្ខខ័ណ្ឌ របស់កម្មវិធីបង់រំលស់ ឬគោលការណ៍និងលក្ខខ័ណ្ឌនៃការផលិតនឹងប្រើប្រាស់ប័ណ្ណឥណទានរបស់ធនាគារ សាខមប៉ែង ខេមបូឌា ឬ

ខ.គណនីប័ណ្ណឥណទានផ្លាស់ប្តូរទៅស្ថានភាពយឺតយ៉ាវក្នុងការសងត្រលប់ ឬម្ចាស់ប័ណ្ណមិនបានធ្វើការទូទាត់បំណុលតាមការកំណត់របស់ ធនាគារសាខមប៉ែង ខេមបូឌា ឬ

គ. គណនីប័ណ្ណឥណទាន ឬកម្មវិធីបង់រំលស់ត្រូវបានរំសាយចោល ដោយម្ចាស់ប័ណ្ណ ឬដោយធនាគារ សាខមប៉ែង ខេមបូឌា ឬពេលដែលម្ចាស់ប័ណ្ណទទួលមរណៈភាព ឬបាត់បង់សមត្ថភាពពលកម្មទាំងស្រុង ជារៀងរហូត។

3.2. ពេលគណនីប័ណ្ណឥណទាន ឬកម្មវិធីបង់រំលស់ត្រូវបានបញ្ឈប់ការប្រើប្រាស់ នោះសមតុល្យដែលនៅសល់របស់ប្រតិបត្តិការណ៍ដែលត្រូវផ្លាស់ប្តូរតាមកម្មវិធីបង់រំលស់នោះ នឹងប្តូរទៅជាចំនួនទឹកប្រាក់ដល់កាលកំណត់ទូទាត់ដោយស្វ័យប្រវត្តិនៅក្នុងគណនីប័ណ្ណឥណទានរបស់អតិថិជន ទៅក្នុងលក្ខខ័ណ្ឌណាក៏ដោយ។

3.3. នៅពេលមានតម្រូវការបញ្ឈប់ការប្រើប្រាស់សេវាកម្មបង់រំលស់ ម្ចាស់ប័ណ្ណត្រូវអនុវត្តន៍ (ក) ហៅមកកាន់ភ្នាក់ងារបំរើអតិថិជនរបស់ធនាគារ សាខមប៉ែង ខេបូឌាតាមរយៈលេខ 023223423 (ខ) ឬមកកាន់សាខាណាមួយរបស់ធនាគារយើងខ្ញុំ។

## 4. ដកការទទួលខុសត្រូវទំហំនៃការទទួលខុសត្រូវ

ធនាគារ សាខមប៉ែង ខេមបូឌានឹងមិនទទួលខុសត្រូវទៅលើផលប៉ះពាល់ ឬការខូចខាតនូវមុខទំនិញ គុណភាពនៃការផ្តល់សេវាកម្ម ក៏ដូចជាការទាមទារតវ៉ាទាំងឡាយណារវាងម្ចាស់ប័ណ្ណ នឹងម្ចាស់ហាងលក់ទំនិញដែលពាក់ព័ន្ធទៅនឹងការទិញទំនិញ ដែលបានចូលរួមកម្មវិធីបង់រំលស់។ ម្ចាស់ប័ណ្ណបានយល់ព្រមឲ្យធនាគារ សាខមប៉ែង ខេមបូឌា ធ្វើការបែងចែកនូវចំនួនសមតុល្យដែលត្រូវធ្វើការទូទាត់ជាច្រើនដង ពេលចុះឈ្មោះប្រើប្រាស់សេវាកម្មបង់រំលស់ទៅលើគណនីប័ណ្ណឥណទានរបស់ខ្លួន បើទោះបីជាមានការទាមទារតវ៉ាណាក៏ដោយ។

## 5. គោលការណ៍ទូទៅ

5.1. ធនាគារ សាខមប៉ែងមានសិទ្ធិទទួលយក ឬបដិសេធនូវរាល់សំណើរសុំចុះឈ្មោះប្រើប្រាស់សេវាកម្មបងរំលស់ណាមួយដោយពុំចាំបាច់បញ្ជាក់ពីមូលហេតុឡើយ។

5.2. នូវរាល់ការកំណត់ណាមួយរបស់គោលការណ៍និងលក្ខខ័ណ្ឌខាងលើនេះ ធនាគារសាខមប៉ែងមានសិទ្ធិ (ក)ផ្អាក់ ឬបញ្ឈប់សេវាកម្មបង់រំលស់ការប្រាក់ 0 % និង/ឬ (ខ)បន្ថែមឬ កែប្រែរការកំណត់ទាំងឡាយណាដែលមាននៅក្នុងគោលការណ៍និងលក្ខខ័ណ្ឌនេះ ដោយធ្វើការជូនដំណឹងទៅកាន់ម្ចាស់ប័ណ្ណនៅពេលវេលាណាមួយ។ ធនាគារសាខមប៉ែងនិងធ្វើការជូនដំណឹងទៅដល់ម្ចាស់ប័ណ្ណដោយមធ្យោបាយណាមួយដែលធនាគារបានកំណត់។

5.3. ធនាគារ សាខមប៉ែង ខេមបូឌា មានសិទ្ធិធ្វើការទំនាក់ទំនងទៅកាន់ម្ចាស់ហាងលក់ទំនិញ អំពើព័ត៌មានរបស់ម្ចាស់ប័ណ្ណនៅក្នុងកម្មវិធីនេះ។

5.4. ម្ចាស់ប័ណ្ណយល់ព្រម ជាមួយធនាគារសាខមប៉ែង ខេមបូឌា ទោះនៅពេលវេលាណាក៏ដោយពុំចាំបាច់ត្រូវធ្វើការជូនដំណឹងជាមុន ឬមានទំនួលខុសត្រូវណាមួយ ធនាគារសាខមប៉ែង មានសិទ្ធិបង្ហាញព័ត៌មានរបស់ម្ចាស់ប័ណ្ណ ឬព័ត៌មានដែលពាក់ព័ន្ធទៅកាន់ភាគីទី៣ ដែលធនាគារយល់ថាសមស្រប។

5.5. រាល់ការកំណត់របស់គោលការណ៍និងលក្ខខ័ណ្ឌនេះនឹងត្រូវអនុវត្តន៍ជាមួយនឹងប្រតិបត្តិការទិញទំនិញប្រើប្រាស់បង់រំលស់ ហើយម្ចាស់ប័ណ្ណត្រូវបានចងដោយគោការណ៍ និងលក្ខខ័ណ្ឌនៃការផលិត និងការប្រើប្រាស់ប័ណ្ណឥណទានរបស់ធនាគារ សាខមប៉ែង ខេមបូឌា និងការព្រមព្រៀងគ្នាផ្សេងទៀតរវាងម្ចាស់ប័ណ្ណនិងធនាគារ។

5.6. ក្នុងករណីមានការមិនត្រូវគ្នារវាងគោលការណ៍និងលក្ខខ័ណ្ឌនេះ ទៅនឹងគោការណ៍ និងលក្ខខ័ណ្ឌនៃការផលិត និងការប្រើប្រាស់ប័ណ្ណឥណទានរបស់ធនាគារ សាខមប៉ែង ខេមបូឌា នោះគោលការណ៍និងលក្ខខ័ណ្ឌខាងលើនេះមានអាទិភាពក្នុងការប្រើប្រាស់ចំពោះប្រតិបត្តិការការទិញទំនិញហើយចូលរួមកម្មវិធីបង់រំលស់។